WORLD BANK GROUP

# ក្របខ័ណ្ឌភាពជាដៃគូសម្រាប់ប្រទេសកម្ពុជា របស់ធនាគារពិភពលោក ឆ្នាំ ២០២៥-២០២៩

## របាយការណ៍សង្ខេបនៃកិច្ចពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ

## ថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០២៣

## សណ្ឋាគារសូហ្វីតែលអង្គរភូគីត្រា ខេត្តសៀមរាប

កិច្ចពិគ្រោះយោបល់លើកទី ៤ ស្តីពីក្របខ័ណ្ឌភាពជាដៃគូប្រចាំប្រទេស (CPF) របស់ធនាគារពិភពលោក ដែលត្រូវបានលើកស្នើឡើងសម្រាប់ឆ្នាំ ២០២៥-២០២៩ ជាមួយនឹងប្រទេសកម្ពុជាត្រូវបានរៀបចំធ្វើឡើងកាលពីថ្ងៃ ១២ ខែធ្នូ ឆ្នាំ ២០២៣ ដោយមានការចូលរួមពីតំណាងចំនួន ៣៦ នាក់ មកពីខេត្តចំនួន ១៤ ៖ (១) សៀមរាប (២) កំពង់ចាម (៣) កំពង់ធំ (៤) ពោធិ៍សាត់ (៥) បាត់ដំបង (៦) ត្បូងឃ្មុំ (៧) ក្រចេះ (៨) មណ្ឌលគិរី (៩) រតនៈគិរី (១០) ស្ទឹងត្រែង (១១) ប៉ៃលិន (១២) ឧត្តរមានជ័យ (១៣) ព្រះវិហារ និង (១៤) បន្ទាយមានជ័យ។ អ្នកចូលរួមប្រមាណពាក់កណ្តាលគឺជាស្ត្រី។

### ទិដ្ឋភាពរួមទូទៅ៖

កិច្ចពិគ្រោះយោបល់នេះចាប់ផ្តើមជាមួយនឹងការថ្លែងសុន្ទរកថាស្វាគមន៍របស់លោកស្រី Maryam Salim អ្នកគ្រប់គ្រងធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា។ បន្ទាប់មក មន្ត្រីធនាគារពិភពលោកបានធ្វើបទបង្ហាញអំពីវឌ្ឍនភាព បញ្ហាប្រឈម និងកាលានុវត្តភាពនៅក្នុងប្រទេសកម្ពុជា ដូចដែលត្រូវបានរកឃើញនៅក្នុងការវិភាគជាប្រព័ន្ធលើស្ថានភាពរបស់ប្រទេស ដែលធ្វើឡើងដោយធនាគារពិភពលោក រួមនឹងការធ្វើបទបង្ហាញអំពីក្របខ័ណ្ឌភាពជាដៃគូដែលត្រូវបានស្នើឡើងនេះ។ លោកអ្នកអាចចូលមើលឯកសារទាំងនេះ តាមរយៈគេហទំព័រកិច្ចពិគ្រោះយោបល់ស្តីពី CPF ឆ្នាំ ២០២៥-២០២៩ សម្រាប់ប្រទេសកម្ពុជា។

អ្នកចូលរួមត្រូវបានបែងចែកជាក្រុម ដើម្បីពិភាក្សាពីលទ្ធផលកម្រិតខ្ពស់ ដោយត្រូវឆ្លើយសំណួរចំនួន ៤ – ខាងក្រោមនេះ គឺជាការបូកសរុបការឆ្លើយតប ដែលទទួលបានពីការពិភាក្សាក្រុមនេះ៖

| |
|---|
| **សំណួរទី ១៖ តើមានបញ្ហាធំៗជាងគេចំនួន ៣ អ្វីខ្លះ ដែលក្រុមធនាគារពិភពលោក (WBG) គួរផ្តោតការយកចិត្តទុកដាក់នៅក្នុងរយៈពេល៤-៥ ឆ្នាំបន្ទាប់?** |
| **លទ្ធផលកម្រិតខ្ពស់ទី ១** – មានការលើកស្នើឱ្យមានការផ្តោតការយកចិត្តទុកដាក់លើការបង្កើនការអប់រំផ្សព្វផ្សាយដល់សហគមន៍ អំពីសារៈសំខាន់នៃការអប់រំកុមារតូច។ ក្រុមនេះក៏បានលើកឡើងពីការបង្កើនការគាំទ្រដល់ការផ្តល់សេវាទារកដ្ឋាននិងសេវាអប់រំកុមារតូច (០-៣ ឆ្នាំ) អាហារូបត្ថម្ភ ជំនាញនៅកម្រិតទាប ដោយបានលើកឡើងជាក់លាក់អំពីបញ្ហាប្រឈមពាក់ព័ន្ធនឹងការទទួលបានសេវាទារកដ្ឋាននៅក្នុងខេត្តកំពង់ចាម។ ចុងក្រោយ អ្នកចូលរួមបានពិភាក្សាពីភាពចាំបាច់នៃការលើកកម្ពស់អភិបាលកិច្ចមូលដ្ឋាន ការចូលរួមរបស់ប្រជាពលរដ្ឋ យេនឌ័រ និងការលើកកម្ពស់សេវាសុខភាព តាមរយៈការផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកសុខាភិបាលជួរមុខ ការបំពាក់សម្ភារៈ និងការផ្តល់ប្រាក់បៀវត្សរ៍ឱ្យបានកាន់តែប្រសើរ។ |

**លទ្ធផលកម្រិតខ្ពស់ទី ២** – អ្នកចូលរួមបានកត់សម្គាល់ពីភាពចាំបាច់ក្នុងការបង្កើនជំនាញឌីជីថល ការគាំទ្រដល់សេវាផ្សព្វផ្សាយកសិកម្ម រួមបញ្ចូលកសិកម្ម ឆ្លាតវៃ និងភាពចាំបាច់ ដើម្បីស្វែងរកទីផ្សារថ្មីៗ សម្រាប់ការនាំចេញកសិផល។ លើសពីនេះ ក៏មានការលើកជាសំណូមពរឱ្យមានការផ្តោតការយកចិត្តទុកសម្រាប់ជនមានពិការភាព នៅក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធនានា ដូចជា សាលារៀន មន្ទីរពេទ្យ និងមណ្ឌលសុខភាព ជាដើម។ ក្រុមនេះបានបញ្ចប់ជាមួយនឹងការលើកឡើងពីភាពចាំបាច់នៃការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងការផ្តល់លទ្ធភាពឱ្យគ្រួសារ និងសហគ្រាសធុនតូច ទទួលបានកម្ចីដែលមានការប្រាក់ទាប។

**លទ្ធផលកម្រិតខ្ពស់ទី ៣** – អ្នកចូលរួមបានលើកឡើងថា ផលចំណេញតិចតួចពីរបរកសិកម្ម កំពុងបង្កផលប៉ះពាល់ធ្ងន់ធ្ងរលើភាពធន់ នឹងភាពក្រីក្រ នៅតាមតំបន់ជនបទ។ មានការលើកសំណូមពរឱ្យធនាគារពិភពលោកជួយកំណត់ពីទីផ្សារ និងធ្វើការងារដែលជួយបង្កើនចំណូលពីរបរកសិកម្ម។ ក្រុមដែលត្រូវបានចាត់តាំងឱ្យធ្វើការពិភាក្សាលទ្ធផលកម្រិតខ្ពស់ទី ៣ ក៏ស្នើឱ្យធនាគារពិភពលោក អនុវត្តគម្រោងកែលម្អការគ្រប់គ្រងធនធានទឹក/ពង្រឹងសន្តិសុខទឹក សម្រាប់វិស័យកសិកម្ម និងផ្តល់ការគាំទ្រដល់ការគ្រប់គ្រងវិស័យជលផល ដើម្បីឆ្លើយតបចំពោះបញ្ហាការនេសាទខុសច្បាប់ និងការគ្រប់គ្រងការនេសាទត្រឹមត្រូវនៅកម្ពុជា។

**សំណួរទី ២៖ ថាតើធនាគារពិភពលោក គួរកាត់បន្ថយសកម្មភាពអ្វីខ្លះនៅក្នុងប្រទេសកម្ពុជា បើគិតពីឧត្តមភាពប្រកួតប្រជែងរបស់ធនាគារពិភពលោក?**

**លទ្ធផលកម្រិតខ្ពស់ទី ១ និងលទ្ធផលកម្រិតខ្ពស់ទី ២** – ក្រុមទាំងពីរនេះពុំមានអនុសាសន៍អំពីអ្វីដែលធនាគារពិភពលោក គួរធ្វើតិចជាងមុននោះឡើយ។ ផ្ទុយទៅវិញ ពួកគេបានលើកឡើងពីលទ្ធភាពពង្រីកការងារឱ្យស្របតាមយុទ្ធសាស្ត្របញ្ចកោណរបស់រដ្ឋាភិបាលកម្ពុជា។

**លទ្ធផលកម្រិតខ្ពស់ទី ៣** – អ្នកចូលរួមបាន ស្នើឱ្យមានការសម្រួល ការត្រួតពិនិត្យ និងការគ្រប់គ្រងគម្រោងរបស់ធនាគារពិភពលោក គួរត្រូវបានសម្រួលដើម្បីកាត់បន្ថយបន្ថយពេលវេលាសម្រាប់ការត្រៀមរៀបចំគម្រោង (ដូចជាការសិក្សាលទ្ធភាព និងការសិក្សាបរិស្ថាននិងសង្គម) ដើម្បីមានពេលគ្រប់គ្រាន់សម្រាប់ការអនុវត្ត។

**សំណួរទី ៣៖ តើអ្នកយល់ឃើញយ៉ាងដូចម្តេចខ្លះ អំពីលទ្ធផលកម្រិតខ្ពស់ និងគោលដៅដែលត្រូវបានដាក់ចេញ សម្រាប់ក្របខ័ណ្ឌ CPF នេះ?**

**លទ្ធផលកម្រិតខ្ពស់ទី ១** - អ្នកចូលរួមឯកភាពជាមួយថាលទ្ធផលកម្រិតខ្ពស់ទាំងពីរ ប៉ុន្តែ ស្នើឱ្យមានការយកចិត្តទុកដាក់លើបរិយាបន្ន និងការគាំទ្រដល់ការលើកកម្ពស់យេនឌ័រ ដើម្បីឱ្យគ្រួសារអាចក្លាយជាកន្លែងកាន់តែប្រសើរ ក្នុងការផ្តល់ឱកាសអប់រំដល់កុមារ។ លើសពីនេះ ក៏មានការស្នើឱ្យមានការឆ្លុះបញ្ចាំងចាត់ទុកការប្រែប្រួលអាកាសធាតុ អភិបាលកិច្ច ការពង្រឹងស្ថាប័ន និងការអប់រំឌីជីថល ថាជាសូចនាករពិនិត្យតាមដានក្រោមលទ្ធផលកម្រិតខ្ពស់ណាមួយ ក្នុងចំណោមលទ្ធផលដែលត្រូវបានស្នើឡើង។ ក្រុមក៏បានពិភាក្សាពីអត្ថប្រយោជន៍នៃការភ្ជាប់ទំនាក់ទំនងឌីជីថល និងការប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម ដើម្បីចូលរួមជាមួយអ្នកទទួលផលរបស់គម្រោង និងប្រជាពលរដ្ឋឱ្យបានកាន់តែសកម្ម ហើយទន្ទឹមគ្នា ផ្តល់ការគាំទ្រដល់យុទ្ធនា

ការផ្លាស់ប្តូរឥរិយាបថ – មានការលើកឡើងពីឧទាហរណ៍ នៃគម្រោងដែលអនុវត្តកាលពីពេលថ្មីៗនេះ ដែលមានការរៀបចំជាយុទ្ធនាការផ្លាស់ប្តូរឥរិយាបថ ជុំវិញការគ្រប់គ្រងសំណល់ ផ្តោតលើយុវជន។

**លទ្ធផលកម្រិតខ្ពស់ទី ២ និងលទ្ធផលកម្រិតខ្ពស់ទី ៣** – អ្នកចូលរួមបានលើកស្នើឱ្យមានការបន្ថែមចីរភាព និងបរិយាបន្នទៅក្នុងចំណុចផ្តោតការយកចិត្តទុកដាក់លើភាពធន់ក្នុងក្របខ័ណ្ឌ CPF ដើម្បីសម្រេចបានលទ្ធផលកាន់តែប្រសើរសម្រាប់ក្រុមដែលងាយរងគ្រោះ។

**សំណួរទី ៤៖ តើធនាគារពិភពលោក អាចឆ្លើយតបចំពោះបញ្ហាប្រឈមឆ្លងវិស័យខាងក្រោមឱ្យបានកាន់តែប្រសើរដោយរបៀបណា៖**

- **ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ**
- **អភិបាលកិច្ច និងសមត្ថភាពស្ថាប័ន**
- **សមភាពយេនឌ័រ និងបរិយាបន្ន**

**លទ្ធផលកម្រិតខ្ពស់ទី ១** – អ្នកចូលរួមផ្តោតការយកចិត្តទុកដាក់លើការគាំទ្រដល់ការលើកកម្ពស់ភាពធន់នឹងអាកាសធាតុនៃហេដ្ឋារចនាសម្ព័ន្ធនានា ដូចជា សាលារៀន មន្ទីរពេទ្យ មណ្ឌលសុខភាព ជាដើម។ ពួកគេបានចែករំលែកបទពិសោធដែលធ្លាប់ឃើញពីការថយចុះ ការប្រើប្រាស់សេវាជាសារវន្ត ក្រោយពេលមានគ្រោះទឹកជំនន់ ដែលបង្កផលប៉ះពាល់ធ្ងន់ធ្ងរលើការអភិវឌ្ឍ។

ដោយឡែកពាក់ព័ន្ធនឹងសមភាព និងបរិយាបន្នវិញ អ្នកចូលរួមបានស្នើឱ្យមានការរៀបចំយុទ្ធនាការផ្លាស់ប្តូរឥរិយាបថពាក់ព័ន្ធនឹងសុខភាព និងការពង្រឹងការផ្សព្វផ្សាយព័ត៌មាន ជាពិសេស ដល់យុវជន ដើម្បីបណ្តុះបណ្តាលឱ្យពួកគេមានជំនាញកាន់តែប្រសើរឡើង ដើម្បីរកប្រាក់ចំណូលបានកាន់តែច្រើន។ អ្នកចូលរួមក៏បានលើកសំណូមពរឱ្យមានការកាត់បន្ថយជំងឺមិនឆ្លង និងផលប៉ះពាល់មកលើសុខភាព ដែលកើតឡើងដោយសារការប្រើគ្រឿងញៀន ថ្នាំជក់ និងគ្រឿងស្រវឹង តាមរយៈការអនុវត្តច្បាប់ឱ្យបានកាន់តែតឹងរ៉ឹង។

**លទ្ធផលកម្រិតខ្ពស់ទី ២** – ការបញ្ជ្រាបការគាំទ្រផ្នែកពិការភាពក្នុងវិស័យនីមួយៗ ត្រូវបានលើកឡើងថា អាចផ្តល់នូវអត្ថប្រយោជន៍ឆ្លងវិស័យជាច្រើន ដល់ការលើកកម្ពស់បរិយាបន្ន។ ដើម្បីឆ្លើយតបចំពោះផលប៉ះពាល់អាកាសធាតុ ដែលជាបញ្ហាប្រឈមឆ្លងវិស័យ អ្នកចូលរួមបានស្នើឱ្យមានការផ្តល់ការគាំទ្របន្ថែមទៀត ដល់ការធ្វើកសិកម្មដែលធន់នឹងអាកាសធាតុ។ ពាក់ព័ន្ធនឹងសមភាពយេនឌ័រវិញ អ្នកចូលរួមបានលើកសំណូមពរឱ្យមានការបណ្តុះបណ្តាល និងការអប់រំផ្សព្វផ្សាយបន្ថែមទៀត ដល់អ្នកដឹកនាំ លើកទឹកចិត្តឱ្យបុរសចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលអំពីយេនឌ័រ និងពង្រីកភាពចម្រុះនៃយេនឌ័រក្នុងវិស័យដែលសំបូរស្ត្រីធ្វើការ។

**លទ្ធផលកម្រិតខ្ពស់ទី ៣** – អ្នកចូលរួមបានគាំទ្រដល់បញ្ហាប្រឈមអន្តរវិស័យ ប៉ុន្តែគិតថាគួរមានការគាំទ្របន្ថែមទៀត ផ្តោតលើការកែទម្រង់នៅថ្នាក់ក្រោមជាតិ ទន្ទឹមនឹងការអនុវត្តកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីកសាងសមត្ថភាពស្ថាប័ន សំដៅអភិវឌ្ឍធនធានមនុស្សនៅថ្នាក់មូលដ្ឋាន។ ក្រុមក៏បាន ស្នើឱ្យមានការពង្រីកការយកចិត្តទុកដាក់លើការគាំទ្រផ្នែកឌីជីថល យេនឌ័រ និងបរិយាបន្ន សម្រាប់ឯកជនមានពិការភាពផងដែរ។